# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧

## ជប៉ុនផ្តល់ថវិកាចំនួន ១,៣៨៩,៨៨៨ ដុល្លារអាមេរិក សម្រាប់ការបង្កើនសមត្ថភាពក្រុមបោសសម្អាតកាកសំណល់ជាតិផ្ទុះពីសង្គ្រាមរបស់CMAC ការពង្រឹងសហគមន៍កសិកម្ម និងការលើកកម្ពស់សុខភាពមាតា និងទារក

ក្រោមគ្រោងការណ៍នៃជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន រដ្ឋាភិបាលជប៉ុនបានយល់ព្រមផ្តល់ថវិកាសរុបចំនួន ១,៣៨៩,៨៨៨ ដុល្លារអាមេរិក ដល់អង្គការក្រៅរដ្ឋាភិបាលជប៉ុនចំនួន៣រួមមានៈ ថវិកាចំនួន ៥៤២,0៥0 ដុល្លារអាមេរិក ផ្តល់ជូនដល់អង្គការសកម្មភាពកម្ចាត់មីនជប៉ុន(JMAS) សម្រាប់គម្រោងបង្កើនសមត្ថភាពក្រុមបោសសម្អាតកាកសំណល់ជាតិផ្ទុះពីសង្គ្រាមរបស់CMAC ដំណាក់កាលទី៣ ថវិកាចំនួន៣៨១,៤0៧ ដុល្លារអាមេរិក ផ្តល់ជូនដល់អង្គការIVY សម្រាប់គម្រោងកាត់បន្ថយភាពក្រីក្រតាមរយៈការពង្រឹងទីផ្សារនៃផលិតផលសរីរាង្គរបស់សហគមន៍កសិកម្មក្នុង២ខេត្ត ដំណាក់កាលទី២ និងថវិកាចំនួន ៤៦៦,៤៣១ ដុល្លារអាមេរិក ផ្តល់ជូនដល់អង្គការWorld Vision Japan សម្រាប់គម្រោងលើកកម្ពស់សុខភាពមាតា និងទារកក្នុងខេត្តតាកែវ ដំណាក់កាលទី១។ កិច្ចសន្យាផ្តល់ជំនួយថ្ងៃនេះ ត្រូវបានចុះហត្ថលេខាដោយ ឯកឧត្តម ហូរីណូអ៊ុជិ ហ៊ីដេហ៊ីសា ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោក ស៊ីបាតា មិគីអុ ប្រធានតំណាងអង្គការJMAS លោកស្រី ម៉ាត់ស៊ូអ៊ូរ៉ា អាយូមិ ប្រធានគម្រោងអង្គការIVY និងលោក ម៉ាត់ស៊ូអុកា តាគូយ៉ា ប្រធានគម្រោងអង្គការWorld Vision Japan នៅស្ថានទូតជប៉ុន។

នៅក្នុងគម្រោងបង្កើនសមត្ថភាពក្រុមបោសសម្អាតកាកសំណល់ជាតិផ្ទុះពីសង្គ្រាមរបស់CMAC ដំណាក់កាលទី៣នេះ អ្នកជំនាញរបស់អង្គការJMAS នឹងបន្តសកម្មភាពបណ្តុះបណ្តាលបន្ថែមទៀតនៅតំបន់ដែលនៅសល់កាកសំណល់ជាតិផ្ទុះពីសង្គ្រាម ក្នុងគោលបំណងបង្កើនសមត្ថភាពបន្ថែមដល់ក្រុមអន្តរាគមន៍បោសសម្អាតកាកសំណល់ជាតិផ្ទុះពីសង្គ្រាម(ERWI) និងគ្រូបង្រៀនរបស់CMAC ព្រមទាំងពិនិត្យនូវលទ្ធភាពនៃការផ្ទេរជំនាញផ្នែកបច្ចេកវិជ្ជាចុងក្រោយបំផុតដូចជា ការប្រើប្រាស់យន្តហោះគ្មានមនុស្សបើក(Drones)ជាដើម។ ជាមួយនឹងគម្រោងនេះ ប្រជាជនប្រមាណជា ២៤0,000នាក់នៅក្នុងតំបន់គោលដៅ នឹងរួចផុតពីការភ័យខ្លាចដោយសារកាកសំណល់ជាតិផ្ទុះពីសង្គ្រាមទាំងអស់នោះ ហើយគម្រោងនេះ នឹងរួមចំណែកក្នុងការកែលម្អបរិស្ថានរស់នៅរបស់ប្រជាជនប្រកបដោយស្ថេរភាព និងអភិវឌ្ឍសហគមន៍ជាបន្តទៅទៀត។

នៅក្នុងគម្រោងកាត់បន្ថយភាពក្រីក្រ តាមរយៈការពង្រឹងទីផ្សារនៃផលិតផលសរីរាង្គរបស់សហគមន៍កសិកម្ម ក្នុង២ខេត្ត នៅដំណាក់កាលទី២ អង្គការIVY នឹងពង្រឹងសមត្ថភាពគ្រប់គ្រងដល់សហគមន៍កសិករ និងសម្ព័ន្ធសហគមន៍កសិករនៅក្នុងខេត្តព្រះវិហារ ព្រមទាំងជួយលើកស្ទួយគុណភាពអង្ករសរីរាង្គ និងបង្កើតប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងមួយដើម្បីទទួលបានវិញ្ញាបនប័ត្រអង្ករសរីរាង្គ។ ដោយផ្តោតលើមជ្ឈមណ្ឌលប្រមូលផ្តុំកសិផលស្វាយរៀង(SAC) ដែលត្រូវបានសាងសង់នៅដំណាក់កាលទី១នៃគម្រោងនេះ ហើយបានក្លាយជាគំរូឈានមុខមួយ អង្គការIVY នឹងជួយSAC ក្នុងការលើកស្ទួយតម្លៃបន្ថែមលើផលិតផលរបស់ខ្លួនប្រកបដោយនិរន្តរភាព ដើម្បីអោយSACអាចដើរតួនាទីជាគំរូមួយកាន់តែជោគជ័យសម្រាប់សហគមន៍កសិកម្មដទៃទៀត។

នៅក្នុងគម្រោងលើកកម្ពស់សុខភាពមាតា និងទារកក្នុងខេត្តតាកែវ ដំណាក់កាលទី១នេះ អង្គការWorld Vision Japan នឹងផ្តល់នូវការបណ្តុះបណ្តាលសម្រាប់បុគ្គលិក និងអ្នកស្ម័គ្រចិត្តសុខាភិបាល និងការអប់រំផ្នែកសុខភាពដល់មាតា នៅក្នុងស្រុកប្រតិបត្តិគិរីវង់ និងស្រុកប្រតិបត្តិកោះអណ្តែត ខេត្តតាកែវ ក្នុងគោលបំណងដើម្បីលើកកម្ពស់គុណភាពនិងការទទួលបាននូវសេវាសុខភាពអោយកាន់តែល្អប្រសើរ និងកាត់បន្ថយអនុបាតកុមារដែលខ្វះអាហារូបត្ថម្ភ និងជម្ងឺនានាដែលឆ្លងតាមទឹកមិនស្អាតជាដើម។ គម្រោងនេះ នឹងធ្វើការបំពាក់សម្ភារៈបរិក្ខារសម្រាប់បន្ទប់ក្រោយសម្រាល និងការកែលម្អបរិក្ខារអនាម័យនៅតាមមណ្ឌលសុខភាព ក្នុងស្រុកប្រតិបត្តិទាំង២។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន បានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ២០០២ ដើម្បីគាំទ្រដល់សកម្មភាពអង្គការក្រៅរដ្ឋាភិបាលជប៉ុនក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍ និងស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកម្រិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២មក រដ្ឋាភិបាលជប៉ុន បានផ្តល់ថវិកាជាង ២៨.៤លានដុល្លាអាមេរិក ដល់គម្រោងចំនួន៩៩ ដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតមូលដ្ឋាន វិស័យសុខាភិបាល វិស័យកសិកម្ម និងសកម្មភាពបោសសម្អាតមីន។ គម្រោងដែលត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ គឺជាគម្រោងទី៤ ទី៥ និងទី៦ តាមរយៈគ្រោងការណ៍នៃជំនួយនេះនៅប្រទេសកម្ពុជា សម្រាប់ឆ្នាំសារពើពន្ធឆ្នាំ២០១៦របស់ជប៉ុន (មេសា២០១៦ ដល់ មិនា២០១៧)៕

---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរស័ព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៨-៣៣០*
*អ៊ីម៉ែល: eco.jpn@.pp.mofa.go.jp*
*គេហទំព័រផ្លូវការ: www.kh.emb-japan.go.jp*
*ហ្វេសប៊ុក: https://www.facebook.com/JapanEmbassyCambodia/*